# រឿងសន្លប់ទឹកទីពីរ...អ្នកឱ្យទឹកចេញក្រៅ !

## ឬ ALLIAGE DEMOCRATIQUE

ដោយ យឹម-កិច្ចសៃ

១- ជជែកវែកញែកចេញក្រដាស់ — មិនផ្លាស់គិតជាតិពេញ <បេះឆ្នោត>
មានតែរង្សីដែលឆ្លាត<ឆោត> — ឲ្យឆ្នោតទុកចិត្តរណឫទ្ធិ (១) ។

២- សម្ព័ន្ធប្រជាធិបតេយ្យ (១) — ខ្លាំងអីគង់ចាញ់ល្បែងជីវិត
ថ្ងៃក្រោយទុកចិត្ត ភូតឬពិត — រួមរឹតរៀនចាំផ្គាំផ្គរភ្លៀង ។

៣- ពុផ្គរចាក់ទឹកចោលចេញអស់ — តើស្មោះប្តូរបក្ខឬប្តូររាង (២)
ប្តូរធាត់ជាស្គមប្តូរអត់ព្រាង — ចំរៀងប្តូរបក្ខហាក់ដូចល្បែង ។

៤-បើក្រុមបក្ខពួកពោលស្នេហ៍ជាតិ — នៅឆ្លៀតចំណោញតែខ្លួនឯង
ខ្មែរនៅវេទនារស់ក្នុងផ្សេង — កន្ត្រែងៗ (៣) ឲ្យបរទេស ។

៥- រង្សីស្គាល់ភ័យរត់ចោលស្រុក — លឿនដូចកំប្រុកមិនមានធ្វេស
ថ្ងៃនេះរួចខ្លួនមិនមានលេស — ចំណោះនៅចាញ់កម្លាំងបាយ ។

៦- រណឫទ្ធិ-ហ៊ុនសែនស្លាប់មិនបាន — ធ្ងន់ប្រាណ<មានស៊ីអត់សែន>ស្តាយ
<ពេញ>ឈ្មោះជាអ្នកនយោបាយ — ឆ្អាំងបាយធ្ងន់ជាងបញ្ហាជាតិ ។

៧- ដុល្លារមាសពេជ្រពាលអំណាច — បន្លាចរាស្ត្រខ្មែរទ្រូងចង្អៀត
ជីវិតខ្វះក្រតាមតទៀត — ព្រោងព្រាតអុំទូកលយប្រទីប ។៚

ក្រុងប៉ែរឡាំង, ថ្ងៃទី៥ កុម្ភ: ឆ្នាំ២០០៥

(១) Alliance Démocratique

(២) "Alliage" démocratique

(៣) *អន្ត្រែង អន្ត្រែង ក្រឡិតក្តងង អន្ត្រែងឲ្យគេ = កាព្យរបស់លោកកេង-វ៉ាន់សាក់ ។ យោងអន្ទិតគោលោត ឆ្នាំ១៩៧៤ ។*